**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១០៩ ព.ណ.គនព.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ២៨អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០១ ស្តីពីការកែសម្រួល និងបំពេញបន្ថែមអនុក្រឹត្យលេខ ៥អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលការត្រួតពិនិត្យគុណភាព សុវត្ថិភាព ផលិតផល និងសេវាកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ១២២ សសរ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា
- យោងប្រកាសលេខ ៣២៩ ព.ណ គនព.ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

- យោងប្រកាសលេខ ៣៥៨ ព.ណ គនព.ប្រក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមឯកទេសផលិតផលហាឡាលកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឲ្យអនុវត្តនូវការបំពេញបែបបទស្នើសុំប្រើប្រាស់ស្លាកសញ្ញា និង / ឬវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ក្នុងគោលបំណងលើកកម្ពស់បច្ចេកទេសស្តង់ដារ អនាម័យ សុវត្ថិភាព និងជំនឿទុកចិត្តពីសាសនិកឥស្លាម និងអ្នកប្រើប្រាស់ទូទៅមកលើផលិតផលហាឡាលកម្ពុជា សម្រាប់ការផ្គត់ផ្គង់ដល់ទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា និងជំរុញការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ។

**ប្រការ ២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងផ្តល់សេវា ផលិត វេចខ្ចប់ ផលិតផល និងសេវារបស់ខ្លួន ដោយមានដាក់ស្លាកសញ្ញាហាឡាល ឬ HALAL ឬ حلال ត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ស្លាកសញ្ញា និង / ឬវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជានៅក្រសួងពាណិជ្ជកម្ម ដោយបំពេញបែបបទ និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំប្រើប្រាស់ស្លាកសញ្ញាហាឡាលកម្ពុជា
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម (ថតចម្លង)
- ប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ និង VAT (ថតចម្លង)
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
- រូបថត ៤x៦ (អ្នកស្នើសុំ) ចំនួន៣សន្លឹក
- សៀវភៅបន្ទុក ឬព័ត៌មានស្តីពី ធាតុផ្សំទាំងឡាយ ដែលពាក់ព័ន្ធ
- ឯកសារពីស្ថាប័នពាក់ព័ន្ធផ្សេងៗ
- HACCP, ISO, GHP, GMP, TQM... បើមាន។

**ប្រការ ៣.-**

ក្រោយពីទទួលបានពាក្យស្នើសុំ លេខាធិការដ្ឋានកិច្ចការហាឡាលកម្ពុជា នឹងចាត់តាំងក្រុមឯកទេសផលិតផលហាឡាលកម្ពុជា ចុះត្រួតពិនិត្យ វាយតម្លៃពីលក្ខខណ្ឌតម្រូវអនុលោមតាមស្តង់ដារបច្ចេកទេសហាឡាល ក្នុងរយៈពេលចាប់ពី ០៣ (បី) ថ្ងៃ (សម្រាប់ការងារនៅលេខាធិការដ្ឋាន) និងមិនលើស ០៣ (បី) ខែឡើយ (សម្រាប់ការងារនៅក្រុមឯកទេសធ្វើការត្រួតពិនិត្យ) ។

ក្នុងករណីដែលក្រុមឯកទេសផលិតផលហាឡាលកម្ពុជា ពិនិត្យឃើញថា គួរអនុញ្ញាតផ្តល់ស្លាកសញ្ញា និង / ឬ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ជូនអ្នកស្នើសុំ គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា នឹងផ្តល់សិទ្ធិប្រើប្រាស់ស្លាកសញ្ញា និង / ឬ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ក្នុងរយៈពេលមិនលើសពី ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

ក្នុងករណីដែលក្រុមឯកទេសពិនិត្យឃើញថាអ្នកស្នើសុំ មិនបានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវ លេខាធិការដ្ឋាននឹងផ្តល់ព័ត៌មានដល់អ្នកស្នើសុំ ដើម្បីធ្វើការកែតម្រូវលើចំណុចខ្វះខាត។

**ប្រការ៤.-**

សុពលភាពស្លាកសញ្ញា និង / ឬ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា មានរយៈពេល ១២ (ដប់ពីរ) ខែ។ អ្នកស្នើសុំត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់ស្លាកសញ្ញា និង / ឬ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដារផលិតផលហាឡាលកម្ពុជា ជាថ្មីឲ្យបាន ០១ (មួយ) ខែមុនពេលអស់សុពលភាព។

**ប្រការ ៥.-**

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាព ឬប្តូរទីតាំងអាជីវកម្មហាឡាល ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ មកលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ឲ្យបានមុន ៣០ (សាមសិប) ថ្ងៃ។

**ប្រការ ៦.-**

ប្រកាស និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

គណៈកម្មាធិការគ្រួតពិនិត្យផលិតផលហាឡាលកម្ពុជា នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រួតពិនិត្យផលិតផលហាឡាលកម្ពុជា ក្រុមឯកទេសផលិតផលហាឡាលកម្ពុជា ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ មេសា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**និងជាប្រធានគណៈកម្មាធិការ**
**គ្រួតពិនិត្យផលិតផលហាឡាលកម្ពុជា**

**ប៉ាន សូរស័ក្តិ**

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ